ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៥

# ប្រកាស

# ស្តីពី

# ការបង្កើតក្រុមផ្តល់ប្រឹក្សាផ្នែកច្បាប់និងគោលនយោបាយ គម្រោងបញ្ជរតែមួយជាតិ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៤/០១៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤ ដែល ប្រកាស ឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួល ពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈ កម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមផ្តល់ប្រឹក្សាផ្នែកច្បាប់និងគោលនយោបាយគម្រោងបញ្ជរតែមួយជាតិ "គ.ច.ប.ជ" ដើម្បីបំពេញមុខងារជាសេនាធិការឲ្យគណៈកម្មការធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ លើបេសកកម្មរៀបចំកសាងច្បាប់និងបទប្បញ្ញត្តិ និងផ្តល់ប្រឹក្សាផ្នែកច្បាប់និងគោលនយោបាយ ពាក់ព័ន្ធនឹងបញ្ជរតែមួយជាតិ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ប៉ែន សំអាត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២. លោក **ឌឹម តារាឬទ្ធិ** | ប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. លោក **ម៉ុរ ម៉ុនណារ៉ា** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. ឯកឧត្តម **ជុន វ៉ាត** | អនុរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៥. លោក **គីមឆាស សុខសីហា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកាំកុងត្រូល | សមាជិក |
| ៦. លោក **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល | សមាជិក |
| ៧. លោក **សរ សិនិវ៉ា** | ប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគ នៃគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ៨. លោក **ចាត សុធីរៈ** | ប្រធាននាយកដ្ឋានបុគ្គលិក នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៩. លោក **ស៊ាង ផល្លា** | អនុប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០. លោក **ទ៉ែន គៀវហាក់** | ប្រធាននាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១១. លោក **ស្រី ស៊ីណា** | អនុប្រធានក្តាប់រួមនៃនាយកដ្ឋាននីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២. លោកស្រី **អេង គីមសួគ៌** | មន្ត្រីនាយកដ្ឋាននីតិកម្ម នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣. លោក **ពិត ច្រាកដ** | នាយកនៃនាយកដ្ឋានអាជីវកម្ម នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ១៤. លោក **ហ៊ីន សុខាល័យ** | ប្រធានអង្គភាពតម្លៃ/ទីផ្សារ នៃកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |

**ប្រការ ២.-**

គ.ច.ប.ជ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ពិនិត្យនិងផ្តល់អនុសាសន៍ លើច្បាប់និងបទប្បញ្ញត្តិ និងគោលនយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍ និងអនុវត្តគម្រោង តាមការស្នើរបស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ ឬ ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ
- កសាងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ សម្រាប់គាំទ្រដល់ការអភិវឌ្ឍនិងអនុវត្តគម្រោង
- ធ្វើរបាយការណ៍វឌ្ឍនភាព ជូនគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំងដោយប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

**ប្រការ ៣.-**

ប្រកាស ឬសេចក្តីសម្រេចណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពនានានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងវិស័យឯកជន ពាក់ព័ន្ធ
- គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ